ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ASIAN INFRASTRUCTURE INVESTMENT BANK

# ផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាននិងសង្គម
# នៃអនុគម្រោងស្តារជួសជុលសាងសង់ផ្លូវ នៃខ្សែផ្លូវកញ្ចប់ទី២
## (ខ្សែផ្លូវភ្ជាប់ពីផ្លូវជាតិលេខ៥ - គោកគ្រួស) ស្រុកកំពង់ត្រឡាច និងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង)

## សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជា ទទួលបានកម្ចីពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលជាហិរញ្ញប្បទាន នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ សម្រាប់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីឆ្លើយតបទៅនឹងការរាលដាលជម្ងឺកូវីដ-១៩។ គម្រោងនេះអនុវត្តចាប់ពីខែកុម្ភៈឆ្នាំ២០២១ ដល់ខែមិថុនាឆ្នាំ២០២៤ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នប្រត្តិបត្តិ ក្នុងខេត្តគោលដៅចំនួន៥ខេត្ត គឺខេត្តកំពង់ឆ្នាំង ព្រៃវែង ត្បូងឃ្មុំ កោះកុងនិងខេត្តប៉ៃលិន។ គោលបំណងរបស់គម្រោងគឺដើម្បី ទ្រទ្រង់ដល់ជីវភាពនិងសេដ្ឋកិច្ចនៅជនបទ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីការរាលដាលជម្ងឺកូវីដ-១៩ និងការបន្សាំនឹងស្ថានភាពបម្រែបម្រួលធាតុអាកាស។ គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ គឺតម្រូវអោយរៀបចំផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាន និងសង្គម។ លើសពីនេះ អ្នកទទួលការក៏ត្រូវរៀបចំផែនការសុវត្ថិភាពបរិស្ថាននិងសង្គម រួមបញ្ចូលទាំងផែនការសុខភាពនិងសុវត្ថិភាពការងារនិងយេនឌ័រ សម្រាប់អនុគម្រោងសាងសង់ផ្លូវជនបទ នៅតាមខេត្តគោលដៅ។

អនុគម្រោងខ្សែផ្លូវកញ្ចប់ទី២ (Lot 2: ខ្សែផ្លូវភ្ជាប់ពីផ្លូវជាតិលេខ៥ - គោកគ្រួស) ស្ថិតនៅក្នុងឃុំសែប ឃុំឈូកស និងឃុំអភិវឌ្ឍន៍ ក្នុងស្រុកកំពង់ត្រឡាចនិងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង មានប្រវែង២០,១៩៥ម៉ែត្រ និងទទឹងប្រវែង៨ម៉ែត្របាននឹងកំពុងស្តារជួសជុលសាងសង់ឡើងវិញ ជាផ្លូវក្រាលកៅស៊ូពីរជាន់និងបេតុងសរសៃដែក។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវរួមមានដូចជា សំណង់លូម្ងូលកាត់ផ្លូវចំនួន៤៥កន្លែង ក្នុងនោះសំណង់លូម្ងូលកាត់ផ្លូវចំនួន៣៤កន្លែង ត្រូវជួសជុលសាងសង់ឡើងវិញ រីឯសំណង់លូម្ងូលចំនួន៨កន្លែងដែលមានស្ថានភាពនៅល្អគឺត្រូវរក្សាទុកដដែល និងសំណង់លូម្ងូល៣កន្លែងផ្សេងទៀតត្រូវដកចេញ។ អនុគម្រោងនេះចាប់ផ្តើមដំណើរការសាងសង់ពីខែមិថុនា ឆ្នាំ២០២៣ រហូតដល់ខែឧសភា ឆ្នាំ២០២៤ ដោយក្រុមហ៊ុន លីមម៉េង ខនស្រ្តាក់សិន &អ៊ីមផតអេចផត (Lim Meng Construction & Import Export Co., Ltd) ជាអ្នកទទួលការសាងសង់ ដែលត្រូវចំណាយថវិកាអស់ ២,៩០៥,៣២០.១២ដុល្លាអាមេរិក។

ការសិក្សាវាយតម្លៃហេតុប៉ះពាល់នៃផែនការសុវត្ថិភាពបរិស្ថាននិងសង្គម គឺបានសិក្សានៅមុនពេលដំណើរការស្តារជួសជុលសាងសង់ផ្លូវ។ លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា ប្រជាពលរដ្ឋចំនួន៩៦គ្រួសារដែលស្ថិតនៅសងខាងផ្លូវ គឺទទួលរងផលប៉ះពាល់នៃការស្តារជួសជុលសាងសង់ផ្លូវនេះ។ ផលប៉ះពាល់បរិស្ថានដែលស្ថិតនៅសងខាងផ្លូវ រួមមាន ដើមឈើចំនួន១៧០ដើម របងឈើនិង ស្រយ៉ាបផ្ទះដែលជាចំណីផ្លូវ។ ប្រជាពលរដ្ឋទទួលរងផលប៉ះពាល់៩៦គ្រួសារនេះ បានឯកភាពនិងផ្តិតស្នាមមេដៃផ្តល់ជូនដោយគ្មានសំណងនៃផលប៉ះពាល់។ លើសពីនេះរដ្ឋបាលស្រុក បានធានាអះអាងបញ្ជាក់ជាលាយល័ក្ខអក្សរពីការមិនប៉ះពាល់ដីធ្លីរបស់ប្រជាពលរដ្ឋ។ ការពិភាក្សាជាសាធារណៈចំនួន២លើកបានរៀបចំឡើង ក្នុងនោះការពិភាក្សាជាសាធារណៈលើកទី១ បានធ្វើនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ១២៦នាក់ (ស្ត្រី១៧នាក់) និងលើកទី២ គឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ មានប្រជាពលរដ្ឋចូលរួមចំនួន ១៨៤នាក់ ក្នុងនោះមានស្ត្រី៤៥នាក់។

ចំពោះយន្តការបណ្តឹងតវ៉ាឬការផ្តល់ពត៌មានពីការត្អូញត្អែរផ្សេងៗ នៅក្នុងកំលុងពេលកំពុងសាងសង់គឺប្រជា-ពលរដ្ឋ អាចផ្តល់ពត៌មានដែលពាក់ព័ន្ធនឹងការស្តារជួសជុលសាងសង់ផ្លូវ ដើម្បីបញ្ចៀសនូវការប៉ះពាល់ជាយថាហេតុណាមួយ ។ យន្តការបណ្តឹងតវ៉ាឬការផ្តល់ពត៌មានពីការត្អូញត្អែរ គឺអាចធ្វើឡើងដោយការជូនជាពត៌មានតាមទូរស័ព្ទឬសរសេរជាលាយល័ក្ខអក្សរផ្តល់ជូនទៅកាន់អាជ្ញាធរមូលដ្ឋាន (មេឃុំ ក្រុមប្រឹក្សាឃុំ ឬមេភូមិ) ឬអ្នកទទួលការសាងសង់ ឬក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទ ឬក៏ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីចូលរួមដោះស្រាយ។ ចំពោះពត៌មានលម្អិតស្តីពីយន្តការបណ្តឹងតវ៉ា គឺមានបិទផ្សាយ និងរក្សាទុកនៅតាមសាលាឃុំ និងការដ្ឋានសាងសង់របស់អ្នកទទួលការ ដែលមានលេខទំនាក់ទំនងតាមគោលដៅនៃអនុគម្រោងនីមួយៗ។